ព្រឹទ្ធសភា

Sen. Kong Korm, chairman of Cambodian Senate Culture & History Committee # 7 and former minister of Foreign Affairs, requests French Republic Senate president Christian Poncelet to re-examine Law No. 49-733 of June 4, 1949 granting sovereignty over Kampuchea Krom to Vietnam.
102607
Courtesy:
The Khmer Kampuchea Krom Community
www.khmerkromngo.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប៉ារីស ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧

**ជូនចំពោះ ឯកឧត្តម CHRISTIAN PONCELET**

**ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង**

ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅពេលនេះជាភ្ញៀវរបស់ព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង ក្នុងទីក្រុងប៉ារីស សូមឯកឧត្តមប្រធានព្រឹទ្ធសភាសាធារណរដ្ឋបារាំងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងអំណរគុណដ៏ជ្រាលជ្រៅរបស់ខ្ញុំ ចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងការបង្កលក្ខណៈគ្រប់យ៉ាងដល់មិត្តភាពសហប្រតិការរវាងព្រឹទ្ធសភាទាំងពីរបារាំង-កម្ពុជានេះ ។

ក្នុងឱកាសនេះ ខ្ញុំសូមឯកឧត្តមប្រធាន និងព្រឹទ្ធសភាបារាំងជួយលើក និងពិនិត្យឡើងវិញ នូវ Loi N° 49.733 du 4 Juin 1949 modifiant le Statut de la Cochinchine dans l'union française ( fait à Toulon, le 4 Juin 1949 ) signé VINCENT AURIOL 1er le Président de la République ជាអាទិ៍ មាន Art.3-En cas de changement du Statut du Vietnam, le Statut de la Cochinchine fera l'objet d'une nouvelle de libération des Assemblées prévues à l'article 75 de la Constitution ( Titre VIII : De l' Union française ) ។ល។

សូមជំរាបឯកឧត្តមប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំងជ្រាបថា ចាប់ពីពេលដែលបារាំងប្រកាសឱ្យប្រើ Loi N°49.733 du 4 Juin 1949 មក ទឹកដី និងពលរដ្ឋខ្មែរដើមកំណើតកម្ពុជាក្រោម ជាពិសេស វប្បធម៌ ភាសា សាសនា ប្រពៃណី ទំនៀមទំលាប់ និងកម្មសិទ្ធិដូនតារបស់ព្រះសង្ឃ និងពលរដ្ឋខ្មែរកម្ពុជាក្រោមត្រូវបានអំណាចវៀតណាមយាយី បំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរជាដរាប ។ ឧទាហរណ៍ៈ វៀតណាមរឹបអូសកម្មសិទ្ធិទឹកដី និងខ្មែរកម្ពុជាក្រោម ហើយបន្តការរំលោភលើកម្ពុជាដែលនៅសេសសល់ ដោយកាន់កាប់ត្រួតត្រាកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាគ្រោះថ្នាក់បង់កម្ពុជាទាំងស្រុង បើគ្មានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងការទទួលស្គាល់ពីអង្គការសហប្រជាជាតិឱ្យសហគមន៍ខ្មែរកម្ពុជាក្រោមបានចូលជាសមាជិកវេទិកាអចិន្ត្រៃយ៍សិទ្ធិជនជាតិដើមនៅអង្គការសហប្រជាជាតិ និងអង្គការ UNPO បានឱ្យសហគមន៍ខ្មែរកម្ពុជាក្រោមចូលជាសមាជិកពេញសិទ្ធិក្នុងមកនោះ ។ ច្បាប់ស្តីពីជនជាតិដើមដែលបង្កើត និងអនុម័តនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ ថ្មីនេះរបស់អង្គការសហប្រជាជាតិ គឺជាមូលដ្ឋានដ៏សំខាន់ សំរាប់កម្ពុជាក្រោម និងខ្មែរដើមកំណើតកម្ពុជាក្រោម ។

យោងផែនទីសណ្ឋានបោះពុម្ពផ្សាយនៅឆ្នាំ១៦៣៤ និងឆ្នាំ១៨៤០ កម្ពុជាក្រោម គឺជាទឹកដីខ្មែរយ៉ាងពិតប្រាកដ ។ ទន្ទឹមនឹងនេះ សូមឯកឧត្តមប្រធាន និងព្រឹទ្ធសភាបារាំងមេត្តាយកចិត្តទុកដាក់ឡើងវិញចំពោះព្រះរាជសារទី១ នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ ព្រះរាជសារទី២ នៅខែវិច្ឆិកា ឆ្នាំ១៨៥៦ របស់ព្រះបាទ អង្គឌួង មហាក្សត្រខ្មែរ ផ្ញើថ្វាយ

ព្រះចៅណាប៉ូឡេអុងទីIII នៃប្រទេសបារាំង អំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជាទៅលើទឹកដីកម្ពុជាក្រោម ។ ដើម្បីបញ្ជាក់ជាថ្មីទៀត អំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជាលើទឹកដីកម្ពុជាក្រោមនេះដែរ ព្រះបាទ នរោត្តម សីហនុ បានរំលឹកអំពីព្រះរាជសាររបស់ព្រះបាទ អង្គឌួង ផ្ញើថ្វាយព្រះចៅណាប៉ូឡេអុងទី III តាមព្រះរាជសារចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៩ ថ្វាយចំពោះព្រះចៅអធិរាជជប៉ុន ជាបន្តទៀតគ្មានដាច់ ។ គ្មានឈប់ឈរតាមសេចក្តីថ្លែងការណ៍ នៅអង្គការសហប្រជាជាតិក្នុងសម័យប្រជុំលើកទី១៦ ព្រះបាទ នរោត្តម សីហនុ បានបដិសេធ និងចាត់ទុកកិច្ចព្រមព្រៀងបារាំង-វៀតណាមឆ្នាំ១៩៤៨ និងច្បាប់បារាំងឆ្នាំ១៩៤៩ ជាមោឃៈ គឺបន្តការទាមទារទឹកដីកម្ពុជាក្រោម ជាកម្មសិទ្ធិស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាជានិច្ច ។

ក្នុងឋានៈជាប្រធានគណៈកម្មការទី៧នៃព្រឹទ្ធសភាព្រះរាជាណាចក្រកម្ពុជា ដែលទទួលកិច្ចការផ្នែក (វប្បធម៌ និង ប្រវត្តិសាស្ត្រ) ខ្ញុំសូមគាំទ្រទាំងស្រុងចំពោះលិខិតថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៣ របស់សហគមន៍ខ្មែរកម្ពុជាក្រោម ដែលសុំឱ្យសភា និងរដ្ឋាភិបាលបារាំងលុបច្បាប់ លេខ ៤៩.៧៣៣ ហើយដែលមានការគាំទ្រពីព្រះមហាវីរក្សត្រ នរោត្តម សីហនុ តាមព្រះរាជសារជូនជនរួមជាតិខ្មែរ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៣ តំណាងយ៉ាងពេញបរិបូណ៌ ឲ្យប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា ។

ដោយយុទ្ធសាស្ត្រលុបបំបាត់ និងស្មានការសន្តិសុខពូជសាសន៍ខ្មែរនៅកម្ពុជាក្រោម ពីសំណាក់សាធារណរដ្ឋសង្គមនិយមវៀតណាមកាន់តែកាចសាហាវឡើងជាលំដាប់នាពេលនេះ ខ្ញុំសូមតាងនាមបងប្អូនដើមកំណើតខ្មែរកម្ពុជាក្រោម និងប្រជាពលរដ្ឋកម្ពុជាទូទៅ គោរពជូនឯកឧត្តមប្រធាន និងសភា ព្រមទាំងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដែលក្នុងអតីតកាលជាអាណាព្យាបាល ហើយក្លាយមកជាសហប្រធាននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ មេត្តាជួយពិនិត្យដោះស្រាយបញ្ហាទាំងឡាយ ដើម្បីទឹកដីកម្ពុជាក្រោម ពលរដ្ឋខ្មែរកម្ពុជាក្រោម និងព្រះរាជាណាចក្រកម្ពុជា បានស្គាល់នូវការពិតដ៏ត្រឹមត្រូវ ស្របតាមការដាក់ស្តែងនៃហេតុផលជាចាំបាច់ ។

សូមឯកឧត្តមប្រធានព្រឹទ្ធសភា និងប្រជាពលរដ្ឋបារាំង ទទួលនូវមនោសញ្ចេតនាមិត្តភាព សហប្រតិបត្តិការ កម្ពុជា-បារាំង រីកចំរើនខ្លាំងក្លាតរៀងទៅ ។

Sen. Kong Korm, chairman of Cambodian Senate Culture & History Committee # 7 and former minister of Foreign Affairs, requests French Republic Senate president Christian Poncelet to re-examine Law No. 49-733 of June 4, 1949 granting sovereignty over Kampuchea Krom to Vietnam, and the on-going encroachment on Cambodia. 102607

Courtesy: The Khmer Kampuchea Krom Community
www.khmerkromngo.org

ហត្ថលេខា

គង់ គាំ

អតីតរដ្ឋមន្ត្រីការបរទេស

ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ព្រះរាជាណាចក្រកម្ពុជា

**ចម្លងជូន :**

- អង្គការសហប្រជាជាតិ *New York* ✓
- រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង
- អង្គការ UNPO

(ដើម្បីជួយពិនិត្យដោះស្រាយ)

- ព្រះមហាវីរក្សត្រ នរោត្តម សីហនុ
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
- សហគមន៍ខ្មែរកម្ពុជាក្រោម

(ជាការគាំទ្រព្រះរាជសារជូនជនរួមជាតិ ៨ មិថុនា ២០០៣)

SENAT
Du Royaume du Cambodge
Nation-Religion-Roi

Sen. Kong Korm, chairman of Cambodian Senate Culture & History Committee # 7 and former minister of Foreign Affairs, requests French Republic Senate president Christian Poncelet to re-examine Law No. 49-733 of June 4, 1949 granting sovereignty over Kampuchea Krom to Vietnam and the on-going encroachment on Cambodia. 102607

Paris, le 26 octobre 2007.

A l'attention de M. Christian PONCELET
Président du Sénat de la République Française

En ma qualité de Président de la 7ème Commission du Sénat du Royaume du Cambodge, en ce moment, hôte du Sénat de la République Française à Paris.

Je tiens à présenter mes respects et mes remerciements les plus sincères à Monsieur le Président du Sénat de la République Française de son accueil chaleureux ainsi que de ses contributions à l'amitié et à la coopération entre le Sénat français et le Sénat cambodgien.

Je profite de cette occasion pour solliciter de votre haute bienveillance la faveur de bien vouloir ré-examiner la Loi n° 49-733 du 4 juin 1949 modifiant le statut de la Cochinchine dans l'Union Française (fait à Toulon, le 4 juin 1949) signée de Vincent AURIOL, 1er Président de la IVème République, en particulier l'article 3 *: en cas de changement du Statut du Vietnam, le Statut de la Cochinchine fera l'objet d'une nouvelle délibération des Assemblées prévues à l'article 75 de la Constitution (Titre VIII : De l'Union française) etc…*

Je vous prie de me permettre de vous rappeler que, depuis la promulgation de la Loi n° 49-733 du 4 juin 1949, le territoire et la population d'origine khmère du Kampuchea Krom, en particulier leur culture, leur langue, leur religion, leurs coutumes et traditions, leurs droits ancestraux se trouvent menacés et détruits petit à petit. La politique de vietnamisation du territoire et de la population khmère du Kampuchea Krom et la poursuite d'agression sur le territoire du Cambodge restant, menées par le gouvernement vietnamien comme l'a montré la tentative d'annexion du Cambodge du 7 janvier 1979, constitueraient le danger de disparition du Cambodge s'il n'y avait pas l'accord de Paris du 23 octobre 1991, la reconnaissance par l'ONU de la Fédération des Khmers du Kampuchea Krom comme membre de l'Instance permanente des peuples autochtones et la reconnaissance par l'organisation UNPO (Organisation des Nations et Peuples non représentés) de la même Fédération comme membre de droit. La loi relative aux personnes appartenant à des minorités nationales et ethniques votée par l'ONU le 13 septembre 2007 constitue la base la plus solide en faveur du Kampuchea Krom et de sa population d'origine khmère.

Selon les cartes géographiques de l'Indochine publiées en 1638 et 1850, Kampuchea Krom faisait réellement partie du territoire cambodgien. Je vous demanderais de vous référer à la lettre n° 1 datée de novembre 1853 et à la lettre n° 2 de novembre 1856 de Sa Majesté Ang Duong, roi du Cambodge, communiquées à l'empereur Napoléon III, relatant la souveraineté du Royaume du Cambodge sur le territoire du Kampuchea Krom. Sur le même sujet, le roi Norodom Sihanouk, en date du 18 juin 1949, a porté à la connaissance de l'empereur du Japon, les missives du roi Ang Duong destinées à Napoléon III. Lors de son intervention à la

16ème Assemblée Générale des Nations Unies, le roi Norodom Sihanouk a considéré comme étant nuls et non avenus les Accords franco-vietnamiens de 1948 ainsi que la Loi française de 1949 : il a affirmé avec véhémence que le territoire du Kampuchea Krom était toujours la propriété légitime du Royaume du Cambodge.

En ma qualité de Président de la 7ème Commission du Sénat du Royaume du Cambodge en charge, entre autres, de la culture et donc de l'histoire, j'apporte mon soutien sans réserve à la résolution du 4 juin 2003 élaborée par la communauté khmère du Kampuchea Krom demandant au Parlement et au gouvernement français d'annuler la Loi n° 49-733, résolution soutenue également par le roi Norodom Sihanouk au nom de son peuple et portée à la connaissance du public cambodgien en date du 8 juin 2003.

Contre la stratégie de plus en plus sauvage d'anéantissement et, à la limite, d'oppression de la population et de la race khmères du Kampuchea Krom, fomentée par la République Socialiste du Vietnam,

Au nom de la population d'origine khmère du Kampuchea Krom et du peuple khmer du Cambodge,

je demanderais avec insistance au Sénat, à l'Assemblée Nationale ainsi qu'au gouvernement français, en leur qualité d'ancien Protecteur du Cambodge et récemment de co-président des Accords de Paris de 1991, de ré-examiner, de résoudre la problématique sur le territoire de Kampuchea Krom, sur sa population d'origine khmère et sur le Royaume du Cambodge afin d'assurer leur pérennité.

En espérant améliorer la coopération entre la France et le Cambodge,

et vous remerciant, je vous prie d'agréer, Monsieur le Président, l'expression de ma considération distinguée.

KONG Korm
Ancien ministre des Affaires Etrangères
Président de la 7ème Commission du Sénat
Du Royaume du Cambodge.

Copie à :

- L'ONU ✓
- Gouvernement de la République Française,
- UNPO

Pour examen et résolution

- Norodom Sihanouk,
- Comité permanent du Sénat,
- Communauté khmère de Kampuchea Krom

Pour soutien au message royal du 8 juin 2003

Sen. Kong Korm, chairman of Cambodian Senate Culture & History Committee # 7 and former minister of Foreign Affairs, requests French Republic Senate president Christian Poncelet to re-examine Law No.: 49-733 of June 4, 1949 granting sovereingty over Kampuchea Krom to Vietnam and the on-going encroachment on Cambodia. 102607

Courtesy: The Khmer Kampuchea Krom Community
www.khmerkromngo.org